# OCIJ Press Release
## សេចក្តីប្រកាសព័ត៌មានរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត

សហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក សូមជំរាបជូនដំណឹងថាការស៊ើបអង្កេតដល់ទីកន្លែងកើតហេតុនៅជើងឯក និងទួលស្លែងកាលពីពេលថ្មីៗនេះ បានបញ្ចប់ប្រកបដោយភាពជោគជ័យ។ សហចៅក្រមស៊ើបអង្កេត សូមថ្លែងអំណរគុណដល់អ្នកដែលពាក់ព័ន្ធនិងជួយសហការជាមួយនឹងតុលាការនេះ។

មានសំនួរខ្លះបានលើកឡើងទាក់ទងទៅនឹងការថត។ ជាការពិតប្រតិបត្តិការស៊ើបអង្កេតទាំងអស់នេះគឺត្រូវប្រព្រឹត្តឡើងដោយសំងាត់ ហើយរាល់សកម្មភាពនានានៃការស៊ើបសួរគឺត្រូវថតដោយមន្ត្រីរបស់អ.វ.ត.កក្នុងគោលបំណងដើម្បីរក្សាទុកជាសំណុំរឿង ។

បន្ថែមលើនេះទៀត ការថតចំលងផ្សេងៗ គឺត្រូវបានធ្វើក្នុងគោលបំណងផ្នែកគរុកោសល្យនិងទុកជាឯកសារ។ ផលិតផលទាំងនេះគឺជាផ្នែកមួយនៃគំរោងឯកសារទូលាយពិពណ៌នាអំពីបញ្ហាបច្ចេកទេសនានាទាក់ទងនឹងដំណាក់កាលស៊ើបអង្កេតនៃដំនើរការទាំងនេះ។ បន្ទាប់ពីបានពិនិត្យមើលនូវជំរើសជាច្រើនរួចមក ក្រុមមួយរួមមានលោក Jean Reynaud និងលោក Remi Lainé ដែលប្រកបវិជ្ជាជីវៈច្បាស់លាស់ ត្រូវបានជ្រើសរើសសំរាប់ឯកសារនេះ។ ពួកគេមានគុណសម្បត្តិស្របច្បាប់និងបទពិសោធន៍នៅក្នុងប្រទេសកម្ពុជាជាពិសេសគឺមានឯកទេសខាងផលិតឯកសារទាក់ទងនឹងតុលាការ។ ពួកគេបានព្រមព្រៀងទាំងអស់ទៅតាមការណែនាំបញ្ជារបស់សហចៅក្រមស៊ើបអង្កេតដែលបានកំណត់។ ដើម្បីឆ្លើយតបទៅនឹងសំនួរដែលបានលើកឡើង សូមបញ្ជាក់ថាពួកគេមិនបានបង់ប្រាក់ឲ្យអ.វ.ត.ក ឬ នរណាម្នាក់អនុញ្ញាតិឲ្យបំពេញការងារទាំងនេះទេ។

ឯកសារនេះនឹងត្រូវបានបញ្ចេញលុះត្រាតែសវនាការនិងបណ្តឹងឧទ្ធរណ៍ទាំងឡាយរបស់ អ.វ.ត.ក បានបញ្ចប់ (ដែលអាចប៉ុន្មានឆ្នាំខាងមុខទៀត) ។ ការត្រួតពិនិត្យទៅលើការសំងាត់រួមទាំងការប្រើប្រាស់ឯកសារទាំងនេះគឺធ្វើឡើងតែនៅក្នុងអ.វ.ត.ក ប៉ុណ្ណោះ ។ ដូច្នេះហើយ គឺគ្មានសំនួរទាក់ទងនឹងការយកព័ត៌មានអំពីការងារស៊ើបអង្កេតនិងការការងារដ៏ទៃនោះទេ។ គរុកោសល្យនិងការរក្សាទុកនៃឯកសារទាំងនេះ គឺធ្វើឡើងនៅក្នុងកាលៈទេសៈតាមការកំនត់ខាងលើ គឺមិនអាចបើកបង្ហាញសំរាប់សារព័ត៌មាន នៅក្នុងពេល

វេលាដែលមានសារៈសំខាន់ហើយការត្រួតពិនិត្យទៅលើខ្លឹមសារដូចបានបញ្ជាក់ខាងលើអាចមានលក្ខណៈមិនសមស្រប។ ជាក់ស្តែង ការងារទាំងនេះមិនអាចធ្វើឡើងដោយគ្មានការយល់ស្របពីសំណាក់ភាគីមេធាវីការពារនោះទេ។

លើសពីនេះទៅទៀត រូបភាពនៃសកម្មភាពស៊ើបអង្កេតទាំងអស់ដែលបានថតដោយក្រុមមួយនេះ នឹងផ្តល់ជូនតាមការសំរេចរបស់តុលាការទៅជូនបុគ្គលណាឬអង្គការណា បន្ទាប់ពីសវនាការនិងបណ្តឹងឧទ្ធរណ៍របស់ អ.វ.ត.ក បានបញ្ចប់។

សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថាការធ្វើឲ្យមានភាពស្មើគ្នាចំពោះការឃ្លាំមើលដែលត្រឹមត្រូវតាមច្បាប់លើតួនាទីរបស់អ្នកសារព័ត៌មាន ជាមួយនឹងលក្ខខណ្ឌចាំបាច់ដែលជាភាពសំងាត់នៃការស៊ើបអង្កេតបែបបនេះ គឺមានលក្ខណៈស្មុកស្មាញ។ ប្រការនេះនឹងងាយស្រួលនៅពេលដែលដំណាក់កាលជាសាធារណៈនៃដំណើរការចាប់ផ្តើម។ ដើម្បីសំរួលទៅដល់បញ្ហាពាក់ព័ន្ធទាំងនេះ សហចៅក្រមស៊ើបអង្កេត សូមឆ្លៀតយកឱកាសនេះជូនដំណឹងថាពួកគេនឹងបោះពុម្ពជាប្រចាំខែនូវរបាយការណ៍ទាក់ទងនឹងសកម្មភាពរបស់ពួកគេតាមសំណុំរឿងផ្សេងៗ៕